ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៧-៥៤០ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ៩

យោងតាមសេចក្តីជូនដំណឹងលេខ ធ៥.០១៧.៤១៥ ស-ជ-ណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការបង្កើនឥណប្រតិទានប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាពទូទាត់ : ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧
- ឥណប្រតិទាន : ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨
- ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ : ៤០.០០០.០០០.០០០ (សែសិបប៊ីលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ២០០.០០០.០០០ (ពីររយលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន)រៀល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD (ជារៀលឬដុល្លារ) ត្រូវមានឥណប្រតិទានយ៉ាងតិច ៣៦៤ថ្ងៃ។ NCD ជាដុល្លារត្រូវកំណត់ Haircut ៥% នៃទឹកប្រាក់ដែលដេញថ្លៃបាន។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈសារអេឡិចត្រូនិក bod_lpco@nbc.org.kh ។ ក្នុងករណីដែលសារអេឡិចត្រូនិកមិនដំណើរការ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ឲ្យបានមុនម៉ោង១២:០០ នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។


សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EX ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh